**ជាតិ សាសនា ព្រះមហាក្សត្រ**
********
**ស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា**
ប្រចាំប្រទេសអង់គ្លេស ដាណឺម៉ាក ហ្វាំងឡង់ អៀរឡង់ ន័រវេ ស៊ុយអ៊ែត
និងអេត្យូពី

**King-Nation-Religion**
********
**Royal Embassy of Cambodia**
to UK – Denmark – Finland – Ireland – Norway – Sweden
& Ethiopia

**ជូនចំពោះ**
**លោកស្រី** Sobopha Owen
ប្រធានសមាគម CASUNIK នៅទីក្រុងឡុងដ៍

**លោកស្រីជាទីរាប់អាន**

ខ្ញុំបានទទួលលិខិតរបស់លោកស្រីហើយ និងសូមថ្លែងអំណរគុណចំពោះលោកស្រី ដែលបានផ្ញើលិខិតជូនពតិមានដល់ខ្ញុំ ពីការលាលែងពីតំណែងជាប្រធានសមាគមខ្មែរប្រចាំចក្រភពអង់គ្លេស (CASUNIK) ។

ខ្ញុំសូមសំដែងនូវការកោតសរសើរដ៏កក់ក្ដៅចំពោះទឹកចិត្តរបស់លោកស្រី ក្នុងការខិតខំបំពេញភារកិច្ច និងកិច្ចខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្ត ប្រាជ្ញា និង ស្មារតី និងបទពិសោធន៍ក្នុងការដឹកនាំសមាគមខ្មែរ CASUNIK អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ និងសូមវាយតម្លៃខ្ពស់ចំពោះស្នាដៃ និងសមិទ្ធផលនានា ដែលសំរេចបានលទ្ធផលល្អប្រសើរក្រោមការដឹកនាំដ៏ឈ្លាសវៃ និងការប៉ិនប្រសព្វរបស់លោកស្រី ។

ទន្ទឹមនេះផងដែរ ខ្ញុំនឹងនៅតែបន្តការគាំទ្របេក្ខភាពលោកស្រី ជាប្រធានសមាគមខ្មែរប្រចាំចក្រភពអង់គ្លេស CASUNIK ជារៀងរហូតដើម្បីដឹកនាំសមាគមខ្មែរ CASUNIK ប្រកបទៅដោយភាពជោគជ័យ ឆន្ទៈម្ចាស់ការ ឧស្សាហ៍ព្យាយាម និងគុណធម៌ដ៏ល្អប្រពៃ ជាពិសេសការថែរក្សាការពារប្រពៃណីជាតិ និងលើកស្ទួយវិស័យវប្បធម៌ ដែលជាកិត្តិយសជាតិខ្មែរ ។

ជាចុងក្រោយនេះ ខ្ញុំសូមជូនពរលោកស្រី សូមទទួលបានជ័យជំនះក្នុងការបោះឆ្នោតជ្រើសរើស ជាថ្មី ជាប្រធានសមាគមខ្មែរប្រចាំចក្រភពអង់គ្លេស (CASUNIK) ក្នុងពេលឆាប់ៗខាងមុខនេះ ។

សូម **លោកស្រី** ទទួលនូវសេចក្ដីរាប់អានដ៏ខ្ពស់ អំពីខ្ញុំ ។

ធ្វើនៅទីក្រុងឡុងដ៍, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣

**ហោ ណាំបូរ៉ា**

64 Brondesbury Park, Willesden Green, London NW6 7AT
Tel: 020 8451 7850 Fax: 020 8451 7594 Web-site: www.cambodianembassy.org.uk E-mail:cambodianembassy@btconnect.com